01644946

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារ D359/38

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/២/០៧-០៩-២០០៩-អវតក/កសចស**

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: **ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 06 / 2020
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ**

**សេចក្តីសម្រេចលើការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ០០៤/២ របស់អង្គបុរេជំនុំជម្រះ**

---

**សហព្រះរាជអាជ្ញា**

ជា លាង
Brenda HOLLIS

**សហមេធាវីការពារក្តី អោ អាន**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")

**រម្លឹកឡើងវិញនូវ** "សេចក្តីសម្រេចលើការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ០០៤/២" របស់ខ្លួន ដែលបានចេញនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ ដែលក្នុងនោះ អង្គបុរេជំនុំជម្រះបានសម្រេចថា អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចមួយស្តីពីការធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារនានា នៅក្នុងសំណុំរឿង ០០៤/២ ក្រោយពេលចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២[១]។

**កត់សម្គាល់ឃើញថា** អង្គជំនុំជម្រះបានចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ របស់ខ្លួនជាសាធារណៈនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩[២]។

**កត់សម្គាល់ឃើញថា** អង្គជំនុំជម្រះនៅតែទទួលយកបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចពីភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[៣]។

**កត់សម្គាល់ឃើញថា** អនុលោមតាមមាត្រា ៩(១) នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង ឯកសារអាចត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញ ឯកសារអាចត្រូវចាត់ប្រភេទសាឡើងវិញ និងដាក់ទៅក្នុងផ្នែកនៃសំណុំរឿងដែលមានកម្រិតសម្ងាត់ខុសគ្នា អនុលោមតាមបទបញ្ជារបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមករណីសមស្រប។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**បង្គាប់ឲ្យ**មន្ត្រីគ្រប់គ្រងសំណុំរឿងនៃផ្នែកគ្រប់គ្រងតុលាការធ្វើចំណាត់ប្រភេទឡើងវិញ ចំពោះឯកសារនានាដែលមានរៀបរាប់នៅក្នុង (១) ឧបសម្ព័ន្ធ I និង II ដែលភ្ជាប់មកជាមួយ ពី "សម្ងាត់"/"កោសលុប

[១] សំណុំរឿង ០០៤/២/០៧-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤/២") សេចក្តីសម្រេចលើការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ០០៤/២ របស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/22 និង D360/31។

[២] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និង D360/33។

[៣] សំណុំរឿង ០០៤/២ បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចពីភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D362/5។

ជាសាធារណៈ” ទៅជា “សាធារណៈ” វិញ និង (២) ឧបសម្ព័ន្ធ III ដែលភ្ជាប់ជាមួយ ពី “សម្ងាត់” ទៅជា “កោសលុបជាសាធារណៈ” វិញ។

**រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០**

**អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន៉ី យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**